ភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការបើកវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ របស់អគ្គនាយកដ្ឋានពន្ធដារ




© *រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*

នាវេលាម៉ោង ៨:៣០នាទី ព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីជំនាញបច្ចេកទេសដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចូលរួមពីសំណាក់ ឯកឧត្តមអគ្គនាយករង ប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ ប្រធានការិយាល័យ និងមន្ត្រីមួយចំនួនទៀត នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីឯកឧត្តម **ស្វាយ សំណាង** អគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍ ជាគ្រូឧទ្ទេសនាម មកពីមហាអយ្យការអមសាលាឧទ្ធរណ៍ នៃក្រសួងយុត្តិធម៌។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានថ្លែងអំណរគុណចំពោះ ឯកឧត្តមអគ្គរង អស់លោក លោកស្រី ជាប្រធាន-អនុប្រធាននាយកដ្ឋាន និងជាប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទូទាំងប្រទេស ដែលមានវត្តមានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ដ៏មានសារៈសំខាន់នេះ ដែលជាសក្ខីកម្មបញ្ជាក់អំពីការខិតខំប្រឹងប្រែងសិក្សាស្វែងយល់ទទួលនូវចំណេះដឹង ពីវគ្គបណ្តុះបណ្តាល ដើម្បីជាប្រយោជន៍ក្នុងការអនុវត្តប្រមូលចំណូលពន្ធឲ្យទទួលបានលទ្ធផលល្អ។

ឯកឧត្តមប្រតិភូ បានជម្រាបជូនសិក្ខាកាមថា មន្ត្រីពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលនូវនីតិសម្បទា ជាមន្ត្រី



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌រួចហើយ តាមរយៈប្រកាសអន្តរក្រសួងរវាង ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលការផ្តល់ជូននេះ គឺជាការផ្តល់សិទ្ធិអំណាចបន្ថែមទៀតជូនដល់ មន្ត្រីពន្ធដារក្នុងការអនុវត្តច្បាប់ឲ្យកាន់តែល្អប្រសើរ ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ ការរៀបចំវគ្គបណ្តុះបណ្តាល ជំនាញបច្ចេកទេសនគរបាលយុត្តិធម៌នេះ គឺជាលក្ខខណ្ឌមួយ ដែលតម្រូវដោយច្បាប់ ដើម្បីឲ្យមន្ត្រីពន្ធដារគ្រប់រូប ដែលបានស្បថនៅចំពោះមុខសាលាឧទ្ធរណ៍ និងនៅតាមបណ្តាសាលាដំបូងរាជធានី ខេត្តនានា ក្លាយជានគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ មកចូលរួមសិក្សារៀនសូត្រ អំពីតួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីឲ្យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួនឲ្យបានពេញលេញ ក្នុងការប្រមូលចំណូលពន្ធ។ ចំពោះវគ្គបណ្តុះបណ្តាលនេះ និងមានមន្ត្រីរាជការពន្ធដារ ដែលជានគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទូទាំងប្រទេសចូលរួមសរុបចំនួន ១ ០៩៨នាក់ សិក្សាមានចំនួន ៦វគ្គ ចាប់ពីថ្ងៃទី ១៤ ដល់ ៣០ ខែមិថុនា ឆ្នាំ២០១៦។

ជាទីបញ្ចប់ ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានផ្តល់ការណែនាំដល់សិក្ខាកាម ដែលជាមន្ត្រីរាជការពន្ធដារនៃអគ្គ-នាយកដ្ឋានពន្ធដារឲ្យខិតខំប្រឹងប្រែង សិក្សាស្វែងយល់ទទួលនូវចំណេះដឹង ពីវគ្គបណ្តុះបណ្តាលនេះ ដើម្បីជាប្រយោជន៍ក្នុងការអនុវត្តប្រមូលចំណូលពន្ធ ឲ្យទទួលបានលទ្ធផលល្អ ព្រមទាំងជូនពរដល់សិក្ខាកាមទាំងអស់ ឲ្យសមប្រកប និងពុទ្ធពរទាំងបួនប្រការគឺអាយុវណ្ណៈសុខៈពលៈកុំបីឃ្លៀងឃ្លាតឡើយ៕


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ